មជ្ឈមណ្ឌលជាតិនៃជនពិការ

មជជព

NCDP

National Centre of Disabled Persons

# គោលការណ៍

# គណៈកម្មាធិការអភិវឌ្ឍន៍ជនពិការតាមសហគមន៍

មជ្ឈមណ្ឌលជាតិនៃជនពិការ
National Centre of Disabled Persons
No.3, Norodom Blvd., Phnom Penh, Cambodia. P.O Box: 170
Tel: (855-23) 210140 ; Fax: (855-23) 213876
E-mail: ncdp_cambodia@online.com.kh
Web site: http://www.ncdpcam.org

# គោលការណ៍

## គណៈកម្មាធិការអភិវឌ្ឍន៍ជនពិការតាមសហគមន៍

- យោងលក្ខន្តិកៈ មជ្ឈមណ្ឌលជាតិនៃជនពិការ
- យោងគោលការណ៍បុគ្គលិក និង គោលការណ៍ផ្សេងៗទៀតរបស់ មជ្ឈមណ្ឌលជាតិនៃជនពិការ
- យោងការរីកចំរើន និង ការវាយតំលៃផែនការយុទ្ធសាស្ត្រ ៣ ឆ្នាំ ២០០៤ –២០០៦ (១៣-១៤/១០/២០០៥)
- យោងសេចក្តីសំរេចកិច្ចប្រជុំ របស់គណៈគ្រប់គ្រងមជ្ឈមណ្ឌលជាតិនៃជនពិការ ថ្ងៃទី ២១-១០-២០០៥

មជ្ឈមណ្ឌលជាតិនៃជនពិការ សំរេចបង្កើតអោយមានគោលការណ៍ គណៈកម្មាធិការអភិវឌ្ឍន៍ជនពិការតាមសហគមន៍ ដែលមានអក្សរកាត់ **គអជស** សរសេរជាភាសារអង់គ្លេស Community Development Committee of People With Disability (CDC-PWD) ដែលមានគោលការណ៍ដូចតទៅ :

**ប្រការ១: គោលបំណងនៃការបង្កើតគណៈកម្មាធិការ**

- នាពេលបច្ចុប្បន្ន សេចក្តីត្រូវការផ្នែក អប់រំ សេដ្ឋកិច្ច និង សង្គម ពិសេសការស្តារកាយសម្បទារបស់ ជនពិការ នៅមានការខ្វះខាត និង ទាមទារអោយមានទំនើបកម្ម សមស្របទៅតាមស្ថានភាពសេដ្ឋកិច្ចសង្គម ។ កត្តាទាំងនេះហើយដែលនាំអោយភ្នាក់ងារអភិវឌ្ឍន៍សហគមន៍ និង គណៈគ្រប់គ្រងរបស់ មជ្ឈមណ្ឌលជាតិនៃជនពិការ បានរកឃើញនីតិវិធី ដើម្បីធានានិរន្តរភាព ដោយបង្កើតអោយមានយន្តការគណៈកម្មាធិការអភិវឌ្ឍន៍ ជនពិការតាមសហគមន៍ ។
- គណៈកម្មាធិការអភិវឌ្ឍន៍ជនពិការតាមសហគមន៍: ត្រូវបានបង្កើតឡើង ដើម្បីពង្រឹងចលនា ជនពិការបន្តពីអង្គការជាតិ រឺ អន្តរជាតិ រឺ បង្កើតជាបណ្តាញអភិវឌ្ឍន៍របស់ជនពិការ នៅតាមថ្នាក់មូលដ្ឋាន ហើយមាន សុឆន្ទៈបំរើការងារដោយឯករាជ្យ មិនបំរើផលប្រយោជន៍គណៈបក្សនយោបាយ តែបំរើផលប្រយោជន៍ ជនពិការ និង សង្គម ហើយជាគណៈកម្មាធិការរកប្រាក់កំរៃសំរាប់បំរើសេវាកម្មជូនជនពិការ ។

**ប្រការ២: រចនាសម្ព័ន្ធ និង សមាសភាពរបស់គណៈកម្មាធិការ**

**ក្រុមប្រឹក្សាភិបាល:** ជាអ្នកប្រឹក្សាផ្តល់យោបល់ និង ជួយគាំទ្រដល់ គអជស។ ក្រុមប្រឹក្សានេះមាន សមាសភាពពី ៣ ទៅ ៥ នាក់ ដែលជា មន្ត្រីថ្នាក់ឃុំមាន : ភ្នាក់ងារសុខភាព ភ្នាក់ងារសង្គមកិច្ច គ្រូបង្រៀន នារីបង្គោល និង មេភូមិ រឺ ឃុំ។ ក្នុងករណីដែលរកពុំបានសមាសភាពមន្ត្រីថ្នាក់ឃុំណា មួយខាងលើអាចជំនួសដោយមន្ត្រីជំនាញ ផ្សេងៗក្នុងតំបន់នោះ ។

**សមាជិកកិត្តិយស:** ជាអ្នកដែលមានឆន្ទៈជួយជនពិការ ទាំងស្មារតី សំភារៈ និង ថវិកា ដូចជា អ្នកជំនួញ, អ្នកមាន ជំនាញ ព្រឹទ្ធាចារ្យ ជាដើម ។

**គណៈកម្មាធិការអភិវឌ្ឍន៍ជនពិការតាមសហគមន៍:** ជាយន្តការធ្វើការដឹកនាំ និង សំរបសំរួលសេវាកម្មរបស់ ជនពិការ នៅក្នុងមូលដ្ឋានរបស់ខ្លួន រួមមាន : សេវាសុខភាព អប់រំ ស្តារកាយសម្បទារ សេវាពតិមាន ឱកាស ការងារ/បង្កើនមុខរបរ និង សិទ្ធិជាវិជ្ជមាន របស់ជនពិការដែលជាសមាជិក ។

**សមាសភាពមាន:**

- ប្រធានមួយរូប ជាជនពិការដែលមកពី កម្មវិធី រឺ គ្រោងការ (របស់ មជជព ដែលកំពុងបំរើ សេវាកម្មជូន ជនពិការក្នុងមូលដ្ឋាននោះផ្ទាល់តែម្តង) រឺ ជាជនពិការដែលមានសមត្ថភាព និង ត្រូវ បានផ្តល់សេចក្តីទុកចិត្ត ដោយមជ្ឍមណ្ឌលជាតិនៃជនពិការ ក្រុមប្រឹក្សាភិបាលរបស់ គអជស និង ជនពិការដែលទទួលផលក្នុងតំបន់ នោះ ដោយសំលេងភាគច្រើនដាច់ខាត ក្នុងចំនួនសមាជិកចូលរួមកិច្ចប្រជុំ។

- អនុប្រធាន/លេខាមួយរូប ជាសមាជិកដែលរស់នៅក្នុងសហគមន៍ និង មានសមត្ថភាព (ពិការ រឺ មិនពិការ) ដែលត្រូវបានស្នើឡើងដោយប្រធាន និង ត្រូវបានផ្តល់សេចក្តីទុកចិត្ត ដោយមជ្ឍមណ្ឌលជាតិនៃជនពិការ ក្រុម ប្រឹក្សាភិបាលរបស់ គអជស និងជនពិការដែលទទួលផលក្នុងតំបន់នោះ ដោយសំលេងភាគច្រើនដាច់ខាត ក្នុង ចំនួនសមាជិកចូលរួមកិច្ចប្រជុំ។

- ហិរញ្ញិកមួយរូប ជាសមាជិក គអជស ដែលមានជំនាញ ហើយត្រូវបានបោះឆ្នោតជ្រើសតាំង ក្នុង សំលេងគាំទ្រ ៥០ភាគរយ បូក ១ ក្រោមការអង្កេតដោយ មជ្ឍមណ្ឌលជាតិនៃជនពិការ រឺ ក្រុមប្រឹក្សាភិបាលរបស់ គអជស។

- សមាជិក គអជស ជាសមាជិកដែលរស់នៅក្នុងសហគមន៏ (ជាអាទិភាពជនពិការ) មកពីភូមិដែលមានជន ពិការ កំពុងទទួលផលប្រយោជន៏។ សមាសភាពសមាជិកនេះ មិនត្រូវបានកំណត់ចំនួនច្បាស់លាស់ទេ ស្ថិតនៅលើ តំរូវការ និង ការជ្រើសរើសរបស់ គអជស ក្នុងតំបន់និមួយៗ។

**ប្រការ៣: អណត្តិរបស់គណៈកម្មាធិការអភិវឌ្ឍន៏ជនពិការតាមសហគមន៍**

ដោយសមាសភាព គអជស ជាអ្នកស្ម័គ្រចិត្តហើយមានបទពិសោធនិវិស័យពិការភាព គអជស នេះ មានអាយុកាល ៣ឆ្នាំ។ រៀងរាល់៣ឆ្នាំម្តង សមាសភាពដែលធ្វើការជ្រើសរើសសមាសភាព គអជស នេះ (**ដូចប្រការ២**) ត្រូវធ្វើការវាយ តំលៃ និងសំរេចអំពីគុណវុឌ្ឍិ ដើម្បីបន្ត រឺ ផ្លាស់ប្តូរ សមាសភាព គអជស ដែលកំពុងកាន់តំណែង។

## ប្រការ៤: ការទទួលខុសត្រូវរបស់គណៈកម្មាធិការអភិវឌ្ឍន៍ជនពិការតាមសហគមន៍

គអជស ត្រូវដឹកនាំ និងអនុវត្តប្រកបដោយ ព្រហ្មវិហារធម៌ យុត្តិធម៌ និងសច្ចៈធម៌ ។

- ជាតំណាងអោយជនពិការក្នុងមូលដ្ឋាន ដែលកំពុងទទួលសេវាកម្ម និងបានចុះបញ្ជីជាសមាជិក របស់ គអជស ។
- បង្កើនទំនាក់ទំនងរវាងជនពិការ អាជ្ញាធរ សមាគម អង្គការជាតិ/អន្តរជាតិ និង ស្ថាប័នឯកជន ទាំងក្នុង និង ក្រៅប្រទេស ដើម្បីផលប្រយោជន៍រួមរបស់ជនពិការក្នុងមូលដ្ឋានរបស់ខ្លួន ។
- បង្កើត និងបង្កើនសេវាកម្មដែលជាសេចក្តីត្រូវការរបស់ជនពិការ ទាក់ទង នឹងគោលបំណងនៃ ការបង្កើត គអជស នេះ ។
- រៀបចំអោយមានអភិបាលកិច្ចល្អ និង តម្លាភាព ជាទំនុកចិត្តរបស់ជនពិការ និង អ្នកពាក់ព័ន្ធ ។
- បង្កើនសមត្ថភាព និងដោះស្រាយស្វែងរកមូលនិធិសំរាប់ទ្រទ្រង់សេវាកម្មជូនជនពិការ និងគអជស ខ្លួនឯងផ្ទាល់
- ធ្វើចលនាដើម្បីសំរេចគោលបំណងកម្មវិធីស្តារ និងការអភិវឌ្ឍន៍សហស្សវត្សរ៍ ព្រមទាំងធ្វើសមាហរណកម្ម ជនពិការលើវិស័យសេដ្ឋកិច្ច និងសង្គម ពិសេសជនពិការទទួលបាននូវសិទ្ធិ គាំពារ និងលើកកំពស់បន្ថែម ។
- ត្រូវដឹកនាំ និងរៀបចំការប្រជុំដោយទៀងទាត់ និងផែនការសកម្មភាព គអជស ធានា និងថែកចាយឯកសារ កាលប្បវត្តិ ។

## ប្រការ៥: ទោសបញ្ញត្តិ

សមាសភាព គអជស ត្រូវបំពេញភារៈកិច្ចរបស់ខ្លួនតាមគោលការណ៍កំណត់ដោយខ្ជាប់ខ្ជួន ។

ត្រូវទទួលខុសត្រូវចំពោះកំហុសឆ្គងដូចតទៅ:

- លួច និង បំផ្លិចបំផ្លាញទ្រព្យសម្បត្តិរួមរបស់ គអជស ត្រូវបញ្ឈប់ពីការងារ គអជស ហើយបង់ ជាសំណង មានតំលៃស្មើនិង របស់ដែលលួច និង បំផ្លិចបំផ្លាញ ឬ ដាក់ពាក្យបណ្តឹងទៅតុលាការ ។

- ក្លែងបន្លំឯកសារ និង ផ្តល់ពត៌មានមិនពិត ត្រូវបញ្ឈប់ពីការងារ គអជស ក្នុងករណីធ្ងន់ធ្ងរ ត្រូវដាក់ពាក្យ បណ្តឹងទៅតុលាការ ។

- បង្កបាតុភាព និង បរិហាកេរ្តិ៍ ដែលនាំអោយមានហាយនភាព ត្រូវធ្វើការព្រមាន ក្នុងករណីធ្ងន់ធ្ងរ ត្រូវបញ្ឈប់ ពីការងារ គអជស ឬ ដាក់បណ្តឹងទៅតុលាការ ។

- រំលោភលើសេចក្តីថ្លៃថ្នូរបស់មនុស្សជាតិ ត្រូវធ្វើការព្រមាន ក្នុងករណីធ្ងន់ធ្ងរ ត្រូវបញ្ឈប់ពី ការងារ គអជស ឬ ដាក់បណ្តឹងទៅតុលាការ ។

**កំណត់សំគាល់:**

គអជស ត្រូវបង្កើតពិន័យរដ្ឋបាល ដើម្បីដោះស្រាយបញ្ហា ដែលមិនទាក់ទិននឹង ការកំណត់ខាងលើ ។

## ប្រការ៦: ការបាត់បង់សុពលភាព និងការរំលាយទៅនៃ គអជស

គអជស នឹងត្រូវបាត់បង់សុពលភាព និងរំលាយនៅក្នុងករណីដែល :

- មជ្ឈមណ្ឌលជាតិនៃជនពិការ និង ជនពិការ លែងត្រូវការតទៅទៀត
- គអជស និង ជនពិការ ផ្តាច់ខ្លួនឯករាជ្យដោយបង្កើតជាសហព័ន្ធ សមាគម និង សហករណ៍
- គអជស អនុវត្តមិនសមស្របទៅតាមគោលបំណងរបស់ខ្លួន
- មានព្យុះសនកម្ម ឬ ហាយនភាព

**កំណត់សំគាល់ :**

ការរំលាយនេះធ្វើទៅបាន លុះត្រាណាមានការស្នើសុំមតិហាសិបភាគរយបូកមួយសំលេង របស់ គអជស និងមានការឯកភាពពី ក្រុមប្រឹក្សាភិបាល គអជស មកកាន់ មជជព ។

## ប្រការ៧: មូលជាធរមាន

គោលការណ៍នេះពុំមានប្រតិសកម្ម និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា និងប្រថាប់ត្រារបស់ មជ្ឈមណ្ឌលជាតិនៃជនពិការ ។ គោលការណ៍នេះត្រូវបានចំលងជូន ភាគីដែលពាក់ពន្ធ័ ដើម្បីជាពតិមាន និងអនុវត្ត ។

ភ្នំពេញ ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៦

នាយកប្រតិបត្តិ

**យី ទាសនា**

បានឃើញ និងអនុម័ត

ប្រធានក្រុមប្រឹក្សាភិបាល

ឯកឧត្តម **អ៊ឹុង ឆាសែាម**